**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧.១៣.០២០.៨២៨ ធ.ស.៧

*ថ្ងៃព្រហស្បតិ៍ ៤កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤*
*រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០*

## សេចក្តីជូនដំណឹង
## ស្តីពី លទ្ធផលនៃកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ លើកទី៥៣

នៅថ្ងៃព្រហស្បតិ៍ ៤កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ៨:៣០ ព្រឹក ធនាគារជាតិនៃកម្ពុជាបានរៀបចំកិច្ចប្រជុំគណៈកម្មាធិការគោល-នយោបាយរូបិយវត្ថុលើកទី៥៣ ក្រោមអធិបតីរបស់ ឯកឧត្តម ទេសាភិបាល និងជាប្រធានគណៈ-កម្មាធិការគោលនយោបាយរូបិយវត្ថុ។ អង្គប្រជុំបានពិភាក្សាលើបច្ចុប្បន្នភាពនៃស្ថានភាពសេដ្ឋកិច្ចពិភពលោក វឌ្ឍនភាព និងបញ្ហាប្រឈមនៃស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា ព្រមទាំងគោលនយោបាយរូបិយវត្ថុសម្រាប់អនុវត្តនាគ្រាខាងមុខ។

ដើម្បីរួមចំណែករក្សាស្ថិរភាពថ្លៃ និងលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុសម្រាប់ត្រីមាសបន្ទាប់ គណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ បានសម្រេចលើជំហរគោលនយោបាយរូបិយវត្ថុ ដូចខាងក្រោម ៖

១/-បន្តរក្សាស្ថិរភាពអត្រាប្តូរប្រាក់ តាមរយៈការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់តាមការចាំបាច់

២/-ផ្តល់អត្រាការប្រាក់អប្បបរមា LPCO ទាប សមស្រប អំណោយផលដល់ការរក្សាអត្រាការប្រាក់លើទីផ្សារដែលគាំទ្រដល់សកម្មភាពសេដ្ឋកិច្ច

៣/-បន្តផ្តល់សន្ទនីយភាពជាប្រាក់រៀលតាមរយៈប្រតិបត្តិការ LPCO ទៅតាមស្ថានភាពអត្រាប្តូរប្រាក់រៀលនិងស្ថានភាពសន្ទនីយភាព និង

៤/-បន្តរក្សាអត្រាប្រាក់បម្រុងកាតព្វកិច្ច ក្នុងអត្រា ៧% ទាំងប្រាក់រៀល និងដុល្លារអាមេរិក រហូតដល់ចុងឆមាសទី១ ឆ្នាំ២០២១ និងតាមការចាំបាច់។

**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**
**ប្រធានគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ**

**ជា-ចាន់តូ**

**ចម្លងជូន ៖**
- សមាជិកគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ
- ឯកសារ-កាលប្បវត្តិ

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧